ផ្នែតហ្វមជណ្តើរការងារចល័ត

(1) វិធីប្រើប្រាស់ជណ្តើរនិងផ្នែតហ្វមការងារចល័ត

ជានិច្ចកាលចូរត្រួតពិនិត្យការដំឡើង!

- វ៉ីសនិងកន្ទាស់ស៊ីកធូរ ធ្លាក់
- របូតវ៉ីស
- ការកំពិតឬខូចខាតទម្រ កាំ និងផ្នែកផ្សេងៗ

(2) ការធ្លាក់ពេលបំពេញការងារដោយសារកម្លាំងប្រតិកម្ម

បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ហាមប្រើកម្លាំងរុញឬទាញ។ វាអាចបណ្តាលឲ្យធ្លាក់ឬដួលដោយសារតែប្រតិកម្ម។
2. ឈរឲ្យត្រង់ខ្លួន។
3. ប្រសិនបើបាត់បង់លំនឹង វាអាចបណ្តាលឲ្យធ្លាក់ឬដួល។

(3) ការធ្លាក់ខណៈពេលឈរនៅលើកាំជណ្ដើរខាងលើ

បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ហាមបំពេញការងារនៅលើកាំខាងលើ។
2. ហាមបំពេញការងារដោយបែរខ្នងទៅកាំជណ្ដើរ។
3. វាអាចបណ្ដាលឲ្យធ្លាក់ឬដួលដោយសារបាត់បង់លំនឹងពីកាំជណ្ដើរ។

(4) ការធ្លាក់នៅពេលចុះដោយខ្នងបែរខ្នងទៅជណ្តើរ

បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ហាមចុះដោយខ្នងបែរខ្នងទៅកាំជណ្តើរ។
2. វាអាចបណ្តាលឲ្យធ្លាក់ឬដួល ប្រសិនបើអ្នកជាន់ខុសកាំជណ្តើរ។
3. ហាមឡើងឬចុះដោយដៃមានកាន់វត្ថុ។
4. នៅពេលឡើងឬចុះ ហាមកាន់វត្ថុ និងលើកដោយប្រើទម្រាបីចំណុច។
   ទម្រាបីចំណុចៈ ទប់ខ្លួនដោយប្រើចំណុច 3 ក្នុងចំណោម 4
   ដោយប្រើដៃនិងជើងទាំងពីរ

(5) ការធ្លាក់នៅពេលដំឡើងនៅលើទីជម្រាល ឬត្រង់កន្លែងដែលមានដីមិនរាបស្មើ។

បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ហាមដំឡើងផ្នែតហ្វមនៅក្នុងកន្លែងដែលមានកម្រិតដីមិនរាបស្មើ។
2. វាអាចបណ្តាលឲ្យធ្លាក់ពីតុការងារដោយសារបាត់បង់លំនឹង។
3. ហាមដំឡើងនៅត្រង់តំបន់ដីមិនរាបស្មើ ជ្រាយ ឬអិល។ ផ្នែតហ្វមការងារអាចបាត់បង់លំនឹងដែលនាំឲ្យធ្លាក់។

(6) មនុស្សពីរនាក់ស្ថិតនៅលើផ្នែតហ្វូមការងារនិងធ្លាក់

បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ហាមមនុស្សពីរឬច្រើននាក់បំពេញការងារនៅលើផ្នែតហ្វូមក្នុងពេលតែមួយ។
2. ប្រសិនបើមនុស្សពីរនាក់បំពេញការងារនៅលើផ្នែតហ្វូមក្នុងពេលតែមួយ ពួកគេអាចប៉ះពារគ្នាហើយអាចបណ្តាលឲ្យធ្លាក់ដោយសារបាត់បង់លំនឹង។

(7) ការធ្លាក់ពីតុការងារនៅកម្រាលខាងលើនៃផ្លែតហ្វូមការងារ

បញ្ហាដែលត្រូវយកចិត្តទុកដាក់

1. ដំឡើងនិងបំពេញការងារនៅត្រង់ផ្លែតហ្វូមដែលមានកម្ពស់សមស្រប។
2. ប្រសិនបើដាក់តុការងារនៅលើកម្រាលផ្លែតហ្វូមការងារ វានឹងបាត់បង់លំនឹងហើយអាចបណ្តាលឲ្យធ្លាក់។
3. ប្រសិនបើអ្នកបំពេញការងារនៅលើផ្លែតហ្វូមការងារមួយទៀត អ្នកត្រូវតែចុះចេញហើយផ្លាស់ទី។
4. ប្រសិនបើអ្នកប្តូរទៅកាន់ផ្លែតហ្វូមមួយទៀត ផ្លែតហ្វូមនោះអាចដួល និងអាចបណ្តាលឲ្យធ្លាក់។

(8) បម្រុងប្រយ័ត្នក្នុងការប្រើប្រាស់ផ្លែតហ្វមការងារចល័តដោយសុវត្ថិភាព (សង្ខេប)

- ហាមឡើង ឬចុះដោយដៃមានកាន់វត្ថុ។ ឡើង ឬចុះដោយដៃកាន់បង្គោលទប់។
- ដំឡើងតុការងារឲ្យស្របទៅនឹងកម្ពស់។ ហាមបំពេញការងារដោយកន្ទែកឬឈរចុងជើង។
- ឈរឲ្យត្រង់ខ្លួន។ ដំឡើងផ្លែតហ្វមការងារឲ្យនឹងនៅជិតរចនាសម្ព័ន្ធសំណង់ ហើយបំពេញការងារនៅលើកម្រាលខាងលើ។
- ហាមទុកឬដាក់វត្ថុមិនចាំបាច់នៅលើកម្រាលខាងលើ។ ការទុកឬដាក់វត្ថុនៅលើផ្លែតហ្វមអាចបណ្តាលឲ្យជំពប់ជើង។ សូមប្រយ័ត្នជើងរបស់អ្នក។
- ហាមរុញឬទាញជញ្ជាំងឬវត្ថុនៅលើផ្លែតហ្វមដោយបង្ខំ។ វាអាចបណ្តាលឲ្យធ្លាក់ដោយសារតែប្រតិកម្ម។
- ហាមរំកិលផ្លែតហ្វមការងារដោយមានវត្ថុនៅលើតុខាងលើ។ មុននឹងរំកិលផ្លែតហ្វមការងារ ចូរយកវត្ថុចេញសិន។
- ហាមដាក់តុឬប្រអប់នៅលើកម្រាលខាងលើហើយបំពេញការងារនៅលើវា។
- ហាមផ្លោះពីផ្លែតហ្វមមួយទៅកាន់ផ្លែតហ្វមមួយទៀត។ អ្នកគួរតែចុះសិនទើបផ្លាស់ទី។
- ហាមមនុស្សលើសពីពីរនាក់បំពេញការងារនៅលើផ្លែតហ្វមក្នុងពេលតែមួយ។